**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា**

**ខេត្តប៉ៃលិន**

លេខ:......១៥..........អយកខ.រប

ប៉ៃលិន.ថ្ងៃទី..១៣...ខែមករា.ឆ្នាំ២០១១

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តប៉ៃលិន**

**គោរពជូន**

**លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ:** ស្តីពីការធ្វើពាក្យស្លោកក្នុងវិទ្យាល័យនៅខេត្តប៉ៃលិន។

**យោង:** លិខិតលេខ:២២២៨ អយក.រប ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមលោកនាយកមេត្តាជ្រាបថា:ចំពោះការស្នើសុំធ្វើពាក្យស្លោកផ្សព្វផ្សាយក្នុងវិទ្យាល័យនៅខេត្តប៉ៃលិន មន្ទីរអនុញ្ញាតិអោយធ្វើពាក្យស្លោកនេះ ប៉ុន្តែខ្លឹមសារសូមយកតាមការសំរេចរបស់ក្រសួងអប់រំ យុវជន និងកីឡា (ក្នុងលិខិតយោងខាងលើ) ។ម្យ៉ាងវិញទៀត មន្ទីរសូមលោកនាយកធ្វើផ្ទាំងផ្សព្វផ្សាយបញ្ឈរ ងាយស្រួលសិស្សានុសិស្សសិក្សាស្វែងយល់ និងសូមសហការជាមួយនាយកវិទ្យាល័យយើងខ្ញុំលើការកំនត់ទីតាំង ដើម្បីរក្សាអោយបាននូវតំលៃសំរាប់ការសិក្សាស្វែងយល់យូរអង្វែង និងសោភ័ណភាពបរិស្ថានទីធ្លាផង។

អាស្រ័យហេតុនេះ សូមលោកនាយកអនុវត្តការងារតាមខ្លឹមសារខាងលើដោយអនុគ្រោះ។ សូមលោកនាយកនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

គង់ ជោតិ

**ចម្លងជូន**

- ក្រសួងអប់រំ យុវជន និងកីឡា
- សាលាខេត្តប៉ៃលិន
  "ជូនជ្រាបជាពត៌មាន"
- គ្រប់វិទ្យាល័យក្នុងខេត្ត
  "ដើម្បីសហការ"
- កាលប្បវត្តិ.ឯកសារ កាវិរដ្ឋបាល